ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខៈ ០៣១ សបក

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី ផលប៉ះពាល់លើប្រជាពលរដ្ឋ និងតំបន់ស៊ីវិល ពីអំពើឈ្លានពានរបស់ភាគីថៃ លើដែនអធិបតេយ្យកម្ពុជា គិតពីម៉ោង៧ព្រឹក រហូតដល់ម៉ោង១២:០០នាទីថ្ងៃត្រង់ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥

ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា សូមជម្រាបជូនសាធារណជនជាតិ និងអន្តរជាតិ ជ្រាបថា **គិតពីម៉ោង៧ព្រឹក ដល់ម៉ោង១២:០០នាទីថ្ងៃត្រង់ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥** នេះ អំពើល្មើសច្បាប់អន្តរជាតិ និងក្បត់បទឈប់បាញ់របស់ភាគីថៃលើដែនអធិបតេយ្យកម្ពុជា ដែលផ្តើមឡើងជាថ្មីទៀតចាប់ពីថ្ងៃទី៧ ខែធ្នូមក នោះ បានបណ្តាលឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសុវត្ថិភាពពលរដ្ឋស៊ីវិល តំបន់ស៊ីវិល និងហេដ្ឋារចនាសម្ព័ន្ធស៊ីវិល ព្រមទាំងបង្អាក់សេវាសាធារណៈជាមូលដ្ឋាន ជាច្រើនកន្លែង ដូចខាងក្រោម៖

**១-ករណីស្លាប់ និងរបួស៖** មានពលរដ្ឋស្លាប់ចំនួន១នាក់ និងរងរបួសស្រាលចំនួន១៤នាក់ នៅខេត្តបន្ទាយមានជ័យ។ ដូច្នេះ គិតពីថ្ងៃទី៧ ខែធ្នូ មកដល់ម៉ោង១២:០០នាទីថ្ងៃត្រង់ ថ្ងៃទី១១ ខែធ្នូ នេះ មានពលរដ្ឋខ្មែរស្លាប់សរុបចំនួន១១នាក់ និងរងរបួសចំនួន៧៤នាក់ ភាគច្រើនកំពុងបន្តសង្គ្រោះបន្ទាន់ដោយក្រុមគ្រូពេទ្យ។

**២-ករណីភៀសសឹក៖ ខេត្តព្រះវិហារ** មានជនភៀសសឹកកើនដល់៦.៦៥៦គ្រួសារ ស្មើនឹងមនុស្សចំនួន២៦.៦៩៦នាក់។ **ខេត្តឧត្តរមានជ័យ** មានជនភៀសសឹកកើនដល់១២.៤០០គ្រួសារ ស្មើនឹងមនុស្សចំនួន៤០.៩៧៤នាក់។ **ខេត្តបន្ទាយមានជ័យ** មានជនភៀសសឹកកើនដល់២៤.៣២៤គ្រួសារ ស្មើនឹងមនុស្សចំនួន៨៥.២៩៥នាក់ (ស្លាប់ម្នាក់អាយុ៧៨ឆ្នាំ នៅជំរំភៀសសឹកស្រុកភ្នំស្រុក)។ **ខេត្តបាត់ដំបង** មានជនភៀសសឹកកើនដល់៤.៥១៣គ្រួសារ ស្មើនឹងមនុស្សចំនួន១៧.៤៥១នាក់។ **ខេត្តពោធិ៍សាត់** មានជនភៀសសឹកកើនដល់ចំនួន ៦៩៧គ្រួសារ ស្មើនឹងមនុស្សចំនួន២.០២៣នាក់។ **ខេត្តកោះកុង** មានជនភៀសសឹកចំនួន១៩៦នាក់ (ភាគច្រើនជាកម្មករសំណង់ និងបុគ្គលិកក្រុមហ៊ុន)។ **ខេត្តប៉ៃលិន** ពុំមានករណីជនភៀសសឹក សភាពការណ៍ធម្មតា។ ចំណែកនៅ**ខេត្តសៀមរាប** បានទទួលជនភៀសសឹកកើនដល់១៦.៧២៤គ្រួសារ ស្មើនឹងមនុស្សចំនួន៥៤.៣៦២នាក់។ សរុបចំនួនជនភៀសសឹកបានកើនដល់ **៦៥.៣១៤គ្រួសារ ស្មើនឹងមនុស្ស២២៦.៩៩៧នាក់**។ ចំនួនប្រជាពលរដ្ឋភៀសសឹកនេះ គិតតែតាមមណ្ឌលសុវត្ថិភាពដែលរៀបចំដោយរដ្ឋបាលដែនដីខេត្តប៉ុណ្ណោះ មិនរាប់បញ្ចូលចំនួនប្រជាពលរដ្ឋភៀសសឹកដែលស្វ័យភៀសសឹកដោយខ្លួនឯង ទៅកាន់ទីកន្លែងសុវត្ថិភាពផ្សេងៗទៀតឡើយ។ រហូតមកដល់រសៀលនេះ នៅតែបន្តមានពលរដ្ឋភៀសសឹកទៅកាន់តំបន់សុវត្ថិភាពគ្រប់មូលដ្ឋានខេត្តពាក់ព័ន្ធជាបន្តបន្ទាប់។

**៣-ករណីបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធស៊ីវិល និងបង្អាក់សេវាសាធារណៈជាមូលដ្ឋាន៖** ពុំទាន់មានរបាយការណ៍ថ្មីនៅឡើយ។ ប៉ុន្តែការប៉ះពាល់ជារួមគឺផ្ទះសំបែង និងសម្ភារប្រើប្រាស់របស់ប្រជាពលរដ្ឋ អគារក្រុមហ៊ុនឯកជន អគាររដ្ឋបាល សាលារៀន វត្តអារាម ប្រាសាទបុរាណ ផ្លូវថ្នល់ និងអង្គភាពសាធារណៈជាច្រើន

កន្លែង បានកំពុងរងការខូចខាតជាបន្តបន្ទាប់ ដោយសារភាគីថៃបានបង្កើនការបាញ់ផ្លោង និងទម្លាក់គ្រាប់ពីយន្តហោះ F16 សំដៅចូលភូមិឋាន និងតំបន់ទីប្រជុំជនស៊ីវិល រហូតដល់ចម្ងាយប្រមាណ៣០គីឡូម៉ែត្រពីព្រំដែន។ សេវាជាមូលដ្ឋានដែលអាជ្ញាធរត្រូវផ្តល់ និងពលរដ្ឋត្រូវទទួលបាន បានផ្អាកស្ទើរទាំងស្រុង ខណៈសាលារៀន **៩០៩កន្លែង** បានបិទទ្វារ និងប៉ះពាល់ដល់ការសិក្សារបស់សិស្សចំនួន**២១៦.១០៧**នាក់ និងគ្រូបង្រៀនចំនួន**៧.៦០១**នាក់។ នេះមិនទាន់គិតពីផលវិបាក នៃផ្សែងពុលដ៏អាក្រក់ ដែលភាគីថៃបន្តប្រើក្នុងប្រតិបត្តិការឈ្លានពានកម្ពុជា ដោយគ្មានសតិសម្បជញ្ញៈ និងផ្ទុយពីច្បាប់អន្តរជាតិ។

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** ប្រកាសគាំទ្រ និងជឿជាក់យ៉ាងមុតមាំ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាអគ្គភស្តុភារជាន់ខ្ពស់ នៃកងកម្លាំងប្រដាប់អាវុធកម្ពុជា និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីដ៏អង់អាច ស្វាហាប់ប្រកបដោយប្រតិភាណរបស់ជាតិ និងប្រជាជន។ ក្រោមការដឹកនាំបញ្ជាប្រកបដោយយុទ្ធសាស្ត្រ និងការផ្តល់យោបល់ប្រកបដោយបទពិសោធន៍ខ្ពស់ របស់ **សម្តេច** ទាំងទ្វេ កម្លាំងកងយោធពលខេមរភូមិន្ទ នៃក្រសួងការពារជាតិ និងនគរបាលការពារព្រំដែនចំណុះក្រសួងមហាផ្ទៃ បានកំពុងប្រកៀកស្មារួមគ្នាការពារបូរណភាពទឹកដី និងអធិបតេយ្យភាពជាតិ ប្រកបដោយភាពម្ចាស់ការ អង់អាចក្លាហាន ឈរជើងយ៉ាងរឹងមាំ និងមានប្រៀបឈ្នះគ្រប់គោលដៅនៃសមរភូមិប្រយុទ្ធ។ ជាមួយគ្នានេះ ថ្នាក់ដឹកនាំ ក្រសួង-ស្ថាប័នគ្រប់វិស័យ រដ្ឋបាលរាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ-សង្កាត់ រួមទាំងមន្ត្រីនគរបាលជាតិ កងរាជអាវុធហត្ថ មន្ត្រីសុខាភិបាល យុវជនស្ម័គ្រចិត្ត( ស.ស.យ.ក កាកបាទក្រហមកម្ពុជា... )ប្រជាការពារ និងជនរួមជាតិគ្រប់មជ្ឈដ្ឋាន បានកំពុងរួមសាមគ្គីគ្នាជួយអន្តរាគមន៍ និងគាំទ្រគ្រប់បែបយ៉ាងជូនវីរយុទ្ធជនជួរមុខ ពលរដ្ឋរងរបួស និងជនភៀសសឹក ប្រកបដោយទំនួលខុសត្រូវក្នុងស្មារតីជាតិនិយមខ្ពស់បំផុត។

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** នៅតែបន្តទទូចដល់សហគមន៍អាស៊ាន អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិ ចូលរួមតាមដាន ថ្កោលទោស និងមានវិធានការច្បាប់ស្របតាមគោលការណ៍នីតិអន្តរជាតិ ចំពោះឧក្រិដ្ឋកម្មដ៏យង់ឃ្នងព្រៃផ្សៃរបស់រដ្ឋាភិបាល យោធា និងកម្លាំងចម្រុះថៃ ដែលបំពានយ៉ាងធ្ងន់ធ្ងរលើធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុសញ្ញាប្រឆាំងការធ្វើទារុណកម្មគ្រប់ទម្រង់ និងធម្មនុញ្ញអាស៊ានជាដើម។ យើងទាមទារឱ្យភាគីថៃ បញ្ឈប់ជាបន្ទាន់ រាល់ឧក្រិដ្ឋកម្មឈ្លានពាន ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាដើម ដោយងាកមកអនុវត្តឱ្យបានពេញលេញតាមបទឈប់បាញ់ ជាពិសេស **សេចក្តីថ្លែងការណ៍រួម ស្តីពីកិច្ចព្រមព្រៀងសន្តិភាពកម្ពុជា-ថៃ** ចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រីប្រទេសទាំងពីរ ដែលមានប្រធានាធិបតីសហរដ្ឋអាមេរិក និងនាយករដ្ឋមន្ត្រីម៉ាឡេស៊ី ចុះហត្ថលេខាជាសាក្សី ព្រមទាំងការថ្លែងស្វាគមន៍គាំទ្រពីមិត្តបរទេស និងសហគមន៍អន្តរជាតិ។

ថ្ងៃ ព្រហស្បតិ៍ ៦រោច ខែ មិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០២៥

**Press Release**
**The Impacts on Civilian Areas, and Casualties Caused by Thailand's Aggression on Cambodia's Sovereign Territory From 7:00 AM until 12:00PM, 11 December 2025**

**The Ministry of Interior of the Royal Government of Cambodia** would like to inform the national and international community that, from 7:00am until 12:00pm on 11 December 2025, the renewed violations of international law and breaches of the ceasefire by the Thai side against Cambodia's sovereign territory since 7 December - caused serious impacts on the safety of civilian populations, civilian areas, and civilian infrastructure, as well as disrupting essential public services in many locations, as follows:

1. **Deaths and Injuries**: 1 civilian have died, and 14 civilians have suffered from minor injuries in Banteay Meanchey province. Therefore, from 7 December up to 12:00pm on 11 December, there have been a total of 11 Cambodian civilian deaths and 74 injuries, most of whom continue to receive emergency medical treatment from medical teams
2. **Displacement of Civilians**: **6,656 families (26,692 people)** have evacuated from Preah Vihear province, **12,400 families (40,974 people)** have evacuated from Oddar Meanchey province, **24,324 families (85,295 people)** have evacuated from Banteay Meanchey province, **4,513 families (17,451 people)** have evacuated from Battambang province, **697 families (2,023 people)** have evacuated from Pursat province, and **196 people** have evacuated from Koh Kong province. Approximately **16,724 families (54,362 people)** have sought shelter in Siem Reap province. This led the total number of displaced civilians to more than **65,314 families** which approximately equal to **226,997 civilians.** These figures of displaced civilians represent only those who have taken refuge at the safety centres organized by the provincial authorities. They do not include those who have self-evacuated to other safe locations on their own. At the same time, as of this afternoon, civilians continue to flee to safety areas across all affected provinces.
3. **Destruction of Civilian Infrastructure and Disruption of Public Services**: Civilian homes and belongings, private company buildings, administrative offices, schools, pagodas, ancient temples, roads, and numerous other public facilities have continued to suffer damage due to Thailand's intensified shelling and F-16 air strikes targeting villages and civilian population centers up to **30km inside Cambodian territory**. It should be noted that all **essential public services** provided by local authorities and needed by the civilians have been entirely halted. A total of **909 public and private schools** has been forced to close, affecting the education of approximately **216,107 students** and **7,601 teachers**. This does not include the harmful consequences of toxic smoke, which Thailand has irresponsibly continued using on Cambodian sovereign territory. **(There are no new figures currently.)**

**The Ministry of Interior of the Royal Government of Cambodia** once again firmly reiterates its full support and unwavering confidence in **Samdech Akka Moha Sena Padei Techo Hun Sen**, President of the Senate and Senior Logistic Commander of the Royal Cambodian Armed Forces, and **Samdech Moha Borvor Thipadei Hun Manet**, the courageous and capable Prime Minister of Cambodia. Under the strategic leadership and experienced guidance of **Samdech Techo** and **Samdech Thipadei**, the forces of the Royal Cambodian Armed Forces and the Border Protection Police have been standing shoulder to shoulder to defend the territorial integrity and national sovereignty with full authority and unwavering strength on every battlefield.

Simultaneously, leaders of ministries, institutions, provincial and municipal administrations, districts, communes, police officers, military police, healthcare workers, youth volunteers (UYFC, Red Cross Cambodia…), community defenders, and citizens nationwide have been united in aiding and full support to frontline forces, injured civilians, and displaced families, fulfilling their duties with a strong spirit of patriotism.

**The Ministry of Interior** continues to urge ASEAN, the United Nations, and the international community to monitor, condemn, and take appropriate measures in accordance with international law, principles, and procedures regarding the brutal and barbaric crimes committed by the Thai government, military, and armed forces, which have gravely violated the UN Charter, the Universal Declaration of Human Rights, the Convention Against Torture, and the ASEAN Charter, among others. Cambodia demands that Thailand immediately cease these wrongful acts and fully comply with the ceasefire terms, especially the Cambodia–Thailand Peace Agreement Joint Declaration, signed by both Prime Ministers with the President of the United States and the Prime Minister of Malaysia and ASEAN Chair as witnesses, and supported by international partners.

Phnom Penh, December 11, 2025